# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៥៧

០២ សីហា ឆ្នាំ២០២១

របាយការណ៍គិតត្រឹមថ្ងៃទី ០២ សីហា ឆ្នាំ២០២១ ម៉ោង១០:០០នាទីព្រឹក

## ស្ថានការណ៍សង្ខេប

### សម្រង់សង្ខេបនៃរបាយការណ៍អំពីស្ថានភាពជំងឺកូវីដ-១៩ ពេលបច្ចុប្បន្ន

- មានករណីវិជ្ជមានវីរុសកូវីដ-១៩ ចំនួនសរុប ៤.៧៧៣ និងករណីស្លាប់ ១៣៧ ត្រូវបានរាយការណ៍នៅក្នុងរយៈពេល ៧ថ្ងៃចុងក្រោយនេះ។ ក្នុងចំណោម ៤.៧៧៣ ករណីនោះ មានករណីនាំចូលចំនួន ១.៨១៩ (៣៨,១ ភាគរយ) និងករណីឆ្លងក្នុងស្រុកចំនួន ២.៩៥៤ ឬស្មើនឹង ៦១,៩ ភាគរយ។
- គិតត្រឹមថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២១ សំណាកសរុបចំនួន ១.៥៣៧ ត្រូវបានធ្វើតេស្តដោយប្រើម៉ាស៊ីនមន្ទីរពិសោធន៍ RT-PCR និងការវិភាគលំដាប់ហ្សែនដើម្បីស្វែងរកវីរុសកូវីដ-១៩បំប្លែងថ្មីទម្រង់ដែលគេព្រួយបារម្ភ (RT-PCR Variant of Concern assays)។ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាកំពុងតែវិភាគកំណត់ពូជនៃកោសិកា (lineage determination) នៅក្នុងស្វែងរកវីរុសកូវីដ-១៩បំប្លែងថ្មី ដោយប្រើម៉ាស៊ីនមន្ទីរពិសោធន៍ RT-PCR និងការវិភាគលំដាប់ហ្សែនទាំងមូល (RT-PCR variant of concern assays and whole genome sequencing)។
- សំណាកសរុបចំនួន ២២៨ ត្រូវបានរកឃើញថាជាវរុសកូវីដ-១៩បំប្លែងថ្មីទម្រង់ដែលតា (Delta variant) ដោយប្រើម៉ាស៊ីនមន្ទីរពិសោធន៍ RT-PCR និងការវិភាគលំដាប់ហ្សែនដើម្បីស្វែងរកវីរុសកូវីដ-១៩បំប្លែងថ្មីទម្រង់ដែលគេព្រួយបារម្ភ៖
    - ១១៩សំណាកពីសមហគមន៍មកពីខេត្តមួយចំនួនក្នុងចន្លោះពីថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២១ និងថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២១
    - ១០៥សំណាក ពីក្នុងចំណោមពលករចំណាកស្រុកត្រលប់មកប្រទេសកម្ពុជាវិញតាមច្រកព្រំដែនគោក។
    - វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ក៏បានរបាយការណ៍ពីការរកឃើញការបំប្លែងខ្លួន E484K (E484K mutation) នៅក្នុងសំណាកពីសហគមន៍ដែលមានវីរុសកូវីដ-១៩បំប្លែងថ្មីទម្រង់អាល់ហ្វា។ ការបំប្លែងថ្មីនេះត្រូវបានរកឃើញនៅទូទាំងពិភពលោក ហើយត្រូវបានកំណត់ថាមានទំនាក់ទំនងនឹងការថយចុះនូវប្រសិទ្ធភាពវ៉ាក់សាំង។
- គិតត្រឹមថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង១០ ម៉ោងសកល មានករណីសរុបចំនួន ៧៨.៤៧៤ ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ១.៤៤២ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជា។ ក្នុងចំណោមនោះ ៧១.៥១៧ករណី បានជាសះស្បើយ។ ករណីនាំចូលពីក្រៅប្រទេសសរុបមានចំនួន ១០.៩៧១ ឬស្មើនឹង ១៤,០ ភាគរយនៃករណីជំងឺកូវីដ-១៩ ទាំងអស់។
- ចាប់តាំងពីខែមករា ឆ្នាំ២០២០ មក មានបុគ្គលចំនួន ១.២១៤.៧៦១នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តបែប Real-Time Polymerase Chain Reaction (RT-PCR) ដោយមានអត្រាវិជ្ជមានក្នុងកម្រិត ៥,០ ភាគរយ។ ជាសរុប គិតត្រឹមថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២១ មានចំនួនតេស្ត ១.៥៧០.៥៣២ ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍។
- កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញយុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បណ្តាលមកពីមេរោគបំប្លែងខ្លួនថ្មីប្រភេទដែលតា (Delta variant) នៅទូទាំងប្រទេសសម្រាប់រយៈពេល ១៤ថ្ងៃ ចាប់ពីថ្ងៃទី ២៩ ខែកក្កដា ដល់ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២១។

## ព្រឹត្តិការណ៍ដែលនឹងកើតមាន និងវិធានការអាទិភាព

**ការតាមដានជំងឺ**

- ក្រសួងសុខាភិបាល ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក កំពុងធ្វើការវាយតម្លៃ និងវិភាគស្ថានភាព និងដំណាក់កាលនៃការចម្លងប្រចាំសប្តាហ៍ ដើម្បីស្វែងយល់អំពីប្រសិទ្ធភាពនៃអន្តរាគមន៍នានា ដោយប្រើប្រព័ន្ធតាមដានជំងឺផ្អែកលើព័ត៌មានច្រើនប្រភពមកពីថ្នាក់ក្រោមជាតិ។
- អង្គការសុខភាពពិភពលោក កំពុងផ្តល់ការគាំទ្រដល់ការត្រួតពិនិត្យមើលលើអត្រានៃការប្រើប្រាស់គ្រែក្នុងបន្ទប់សង្គ្រោះបន្ទាន់នៅកម្រិតថ្នាក់ក្រោមជាតិ។
- អង្គការសុខភាពពិភពលោក បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួងសុខាភិបាលនៅក្នុងការរៀបចំបង្កើត ពិនិត្យមើលឡើងវិញ និងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រតាមដានជំងឺកូវីដ-១៩ ដើម្បីរៀបចំធ្វើការឆ្លើយតប។
- អង្គការសុខភាពពិភពលោក នឹងបន្តផ្តល់ការគាំទ្រដល់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាលនៅក្នុងការពង្រឹងសមត្ថភាពតាមដានជំងឺដោយប្រើព័ត៌មានមកពីច្រើនប្រភព ការតាមរកអ្នកប៉ះពាល់អ្នកជំងឺកូវីដ-១៩ និងការវាយតម្លៃហានិភ័យនៅក្នុងខេត្តចំនួន៦បន្ថែមទៀត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**មន្ទីរពិសោធន៍**

- វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា អង្គការសុខភាពពិភពលោក និងអង្គការដៃគូផ្សេងទៀត កំពុងជួយគាំទ្រផ្នែកបច្ចេកទេស និងផ្នែកសម្របសម្រួលដល់វិទ្យាស្ថានជាតិសុខភាពសាធារណៈ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល និងមន្ទីរពិសោធន៍វីរុសកូវីដ-១៩ ដើម្បីធានាឲ្យមាននិរន្តរភាពនៃសមត្ថភាពធ្វើតេស្ត។
- ការរៀបចំការធ្វើតេស្តរកមេរោគកូវីដ-១៩ កំពុងត្រូវបានធ្វើឡើងនៅមន្ទីរពិសោធន៍ដែលទើបតែសាងសង់ថ្មីនៅខេត្តបាត់ដំបង និងខេត្តសៀមរាប។

**អន្តរាគមន៍ និងការផ្តល់សេវាសុខភាព**

- ក្រសួងសុខាភិបាលកំពុងតែបង្កើយកំណែប្រែទី៥នៃពិធីសារសម្រាប់ការវិភាគរកមេរោគ និងការព្យាបាល។
- ក្រសួងសុខាភិបាល ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការសុខភាពពិភពលោក និងដៃគូអភិវឌ្ឍន៍ កំពុងរៀបចំឯកសារសំខាន់ៗដូចជា៖
    - ❖ ពិធីសារអំពីការព្យាបាលជំងឺកូវីដ-១៩សម្រាប់កុមារ
    - ❖ កំពុងធ្វើបង្កើយនូវសម្ភារសម្រាប់បណ្តុះបណ្តាលអំពីការព្យាបាលដោយប្រើអុកស៊ីសែន
    - ❖ ការរៀបចំបង្កើតគោលការណ៍ណែនាំអំពីការបង្កើនគ្រែសង្គ្រោះបន្ទាន់ និងការបន្តផ្តល់សេវាសុខភាពសំខាន់ៗ
    - ❖ ផលិតឯកសារសម្រាប់ការប្រាស្រ័យទាក់ទងអំពីការរកឃើញ និងព្យាបាលជំងឺកូវីដ-១៩ បានឆាប់រហ័សដោយផ្តោតជាសំខាន់លើសហគមន៍ និងបុគ្គលិកសុខាភិបាល និង
    - ❖ ការរៀបចំផែនការត្រៀមទុកអុកស៊ីសែន

**ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍**

- យុទ្ធសាស្ត្រអំពីការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍ ត្រូវបានធ្វើបច្ចុប្បន្នភាពស្របទៅតាមលទ្ធផលរកឃើញនាពេលថ្មីៗនេះរបស់ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក បន្ទាប់បានធ្វើបេសកកម្មចុះជួយបណ្តាខេត្តក្នុងការត្រៀមរៀបចំខ្លួនឆ្លើយតបនឹងជំងឺកូវីដ-១៩ និងលទ្ធផលស្ទង់មតិអំពីការយល់ដឹង និងអាកប្បកិរិយាចំពោះជំងឺកូវីដ-១៩កាលពីខែឧសភា ហើយនិងផែនការឆ្លើយតបនឹងជំងឺកូវីដ-១៩ដែលទើបនឹងត្រូវបានធ្វើបច្ចុប្បន្នភាពថ្មី ។
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានដាក់ឲ្យអនុវត្តនូវយុទ្ធនាការអប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាពលរដ្ឋ ក្រោមប្រធានបទរួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ដើម្បីជម្រុញការទទួលខុសត្រូវរបស់បុគ្គល គ្រួសារ សហគមន៍ ស្ថាប័នពាក់ព័ន្ធជាពិសេសសេវាឯកជន អាជ្ញាធរមូលដ្ឋាន ក្នុងស្មារតីសាមគ្គីភាពដើម្បីកាត់ផ្តាច់ខ្សែចម្លងវីរុសកូវីដ-១៩ ព្រមទាំងរស់នៅជាមួយនឹងវីរុសកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មីឲ្យបានត្រឹមត្រូវ។
- អង្គការសុខភាពពិភពលោក នឹងផ្តល់ការគាំទ្រដល់ក្រសួងសុខាភិបាល នៅក្នុងការដាក់ឲ្យអនុវត្តនូវគម្រោងជម្រុញឲ្យមានការចូលរួមរបស់សហគមន៍ក្នុងអំឡុងពេលនៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងបន្តទៅអនាគត ដោយផ្តល់ការគាំទ្រដល់រៀបចំយុទ្ធសាស្ត្រជម្រុញការចូលរួមរបស់សហគមន៍ថ្នាក់ជាតិ និងការត្រៀមខ្លួន និងផែនការឆ្លើយតបចំពោះបញ្ហាកូវីដ-១៩របស់រាជធានី-ខេត្ត។
- ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក បន្តផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនទាក់ទងនឹងស្ថានភាពជំងឺកូវីដ-១៩ និងបង្កើនការយល់ដឹងរបស់សាធារណជនដើម្បីបន្តអនុវត្តវិធានការការពារខ្លួន និងវិធានការសង្គម។
- អង្គការសុខភាពពិភពលោក និងដៃគូ បន្តជម្រុញការចូលរួមរបស់សហគមន៍យ៉ាងសកម្មដោយផ្តោតជាសំខាន់ទៅលើកន្លែងដែលមានហានិភ័យខ្ពស់ ដើម្បីកាត់បន្ថយការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។
- អង្គការសុខភាពពិភពលោក បន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ភ្នាក់ងារអង្គការសហប្រជាជាតិដទៃទៀត និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការពង្រឹងអន្តាគមន៍សម្រាប់ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍ ប្លុករួមទាំងការផលិតឯកសារតាមតម្រូវការចាំបាច់។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## ការវាយតម្លៃពីការចម្លង

ការវាយតម្លៃលើការតាមដានជំងឺដោយប្រើព័ត៌មានពីប្រភពចម្រុះនាពេលបច្ចុប្បន្ន បង្ហាញថា រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកណ្ដាល ខេត្តតាកែវ ខេត្តកំពត ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប ស្ថិតនៅក្នុងដំណាក់កាលចម្លងទី២ (ការចម្លងកម្រិតសហគមន៍នៅតាមតំបន់) ហើយខេត្តចំនួន១៣ផ្សេងទៀត (ខេត្តកោះកុង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តបាត់ដំបង ខេត្តកែប ខេត្តក្រចេះ ខេត្តប៉ៃលិន ខេត្តពោធិសាត់ ខេត្តខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី ខេត្តឧត្តរមានជ័យ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី) មានករណីស្ថិតនៅក្នុងដំណាក់កាលចម្លងទី១។

| | | | | |
|---|---|---|---|---|
| បច្ចុប្បន្នភាពអេពីដេមីសាស្ត្រអំពីកូវីដ-១៩ | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | |
| | **80,109**<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល៧ថ្ងៃចុងក្រោយ | **4,773**<br>ករណីវិជ្ជមានថ្មីក្នុងពេល៧ថ្ងៃចុងក្រោយ<br>(៦,០ ភាគរយ - ៧ថ្ងៃ) | **137**<br>ករណីស្លាប់ក្នុងពេល៧ថ្ងៃចុងក្រោយ<br>(៩,៥ ភាគរយ - ៧ថ្ងៃ) | **7,631**<br>ករណីនាំចូលក្នុងពេល២៨ថ្ងៃចុងក្រោយ |
| | **1, 570,532**<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | **78,474**<br>ករណីសរុប | **1,442**<br>ករណីស្លាប់សរុប | |
| ការផ្ដល់សេវាសុខភាពអំពីកូវីដ-១៩ | **27**<br>ចំនួនមន្ទីរពេទ្យដែលទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ | **13,782**<br>ចំនួនគ្រែមន្ទីរពេទ្យរដ្ឋ | **37**<br>ចំនួនមន្ទីរពេទ្យដែលមានបទពិសោធន៍គ្រប់គ្រងករណីជំងឺកូវីដ-១៩ (រួមបញ្ចូលមូលដ្ឋានសុខភាពប្រើជាមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ ចំនួន១០) | |

## អេពីដេមីសាស្ត្រ

ក្រាហ្វិកទី១. ខ្សែកោងអេពីដេមីសាស្ត្រនៃករណីជំងឺកូវីដ-១៩ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

ក្រាហ្វិកទី២. ចំនួនករណីជំងឺស្រដៀងផ្ដាសាយ (ILI) មកពីកន្លែងតាមដានជំងឺស្រដៀងផ្ដាសាយ (ចំនួន ៧កន្លែង) ប្រចាំសប្ដាហ៍ ឆ្នាំ២០២១ និងពីឆ្នាំ២០១៨ ដល់ឆ្នាំ ២០២០

*ការរាយការណ៍ពីកន្លែងតាមដានជំងឺស្រដៀងផ្ដាសាយខ្លះមានការយឺតយ៉ាវ នៅក្នុងប៉ុន្មានសប្ដាហ៍នេះ




ក្រាហ្វិកទី៣. ចំនួនករណីជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ ប្រចាំសប្ដាហ៍ ឆ្នាំ២០២១ និងពីឆ្នាំ២០១៨ ដល់២០២០






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# អភិក្រមយុទ្ធសាស្ត្រ

**ការឆ្លើយតបសុខភាពសាធារណៈនៅថ្នាក់ជាតិ និងរាជធានី-ខេត្ត**

## ប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ

- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ដែលមានសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីជាប្រធាន
    - គណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ដែលមានឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន
    - គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ថ្នាក់រាជធានី-ខេត្តដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
    - គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ក្នុងក្របខណ្ឌទូទាំងប្រទេស
    - គណៈកម្មការចំពោះកិច្ចទទួលបន្ទុកលទ្ធកម្មវ៉ាក់សាំងកូវីដ-១៩
- គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលជាប្រធាន និងអមដោយរដ្ឋលេខាធិការ
    - អនុគណៈកម្មការវាយតម្លៃ ផែនការ និងយុទ្ធសាស្ត្រដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័កដឹកនាំដោយអគ្គនាយកស្រាវជ្រាវចារកិច្ចក្រសួងការពារជាតិ
    - អនុគណៈកម្មការឆ្លើយតបបន្ទាន់ និងស្រាវជ្រាវរកបុគ្គលផ្ទុកមេរោគកូវីដ-១៩ ដឹកនាំដោយអគ្គស្នងការរងនគរបាលជាតិក្រសួងមហាផ្ទៃ
    - អនុគណៈកម្មការបច្ចេកទេស និងព្យាបាល ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - អនុគណៈកម្មការសេវាមន្ទីរពិសោធន៍ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - អនុគណៈកម្មការបច្ចេកទេស និងទិន្នន័យ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
    - អនុគណៈកម្មការផ្គត់ផ្គង់ និងហិរញ្ញវត្ថុ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - អនុគណៈកម្មការសាងសង់ និងជួសជុល ដឹកនាំដោយអគ្គស្នងការរងនគរបាលជាតិក្រសួងមហាផ្ទៃ
    - អនុគណៈកម្មការគ្រប់គ្រង និងចាត់ចែងសាកសពអ្នកជំងឺកូវីដ-១៩ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងមហាផ្ទៃ
- គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានក្រុមការងារបច្ចេកទេស៤ក្រុមសម្រាប់ដោះស្រាយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមបង្កឡើងដោយជំងឺកូវីដ-១៩

## ការអភិវឌ្ឍប្រព័ន្ធ និងគោលនយោបាយ

- កាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ ២០២១ សេចក្តីព្រៀងច្បាប់ស្តីអំពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ត្រូវបានអនុម័តដោយរដ្ឋសភា។
- ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រឹត្យនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ មិនទាន់ត្រូវបានអនុវត្តនៅឡើយទេ។
- ទំរង់ Go.Data (Go.Data Platform) ត្រូវបានប្រើជាមូលដ្ឋានទិន្នន័យមួយសម្រាប់ប្រមូលព័ត៌មានអំពីអ្នកប៉ះពាល់ជាមួយករណីកូវីដ-១៩ វិជ្ជមាន និងព័ត៌មានមន្ទីរពិសោធន៍។
- មូលដ្ឋានទិន្នន័យរបស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ត្រូវបានកែសម្រួលដើម្បីអាចបញ្ចូលសំណុំទិន្នន័យប្រភពច្រើនសម្រាប់ការធ្វើតេស្ត និងតាមដានជំងឺ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

### គន្លឹះអាទិភាពសំខាន់ៗ

- ○ អង្គការសុខភាពពិភពលោក បានផ្តល់ការគាំទ្រដល់ក្រសួងសុខាភិបាលដើម្បីចុះបេសកកម្មទៅតាមបណ្តាខេត្តនានាក្នុងអំឡុងខែមិថុនា ដើម្បីជួយខេត្តក្នុងការត្រៀមរៀបចំខ្លួន និងឆ្លើយតបនឹងជំងឺកូវីដ-១៩។
- ○ នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងធ្វើការស្ទង់មតិមួយអំពីវគ្គបណ្តុះបណ្តាលកន្លងមកពីការគ្រប់គ្រងគ្លីនិក ការបង្ការនិងត្រួតពិនិត្យការឆ្លងរោគ ដើម្បីរៀបចំបង្កើតកម្មវិធីសិក្សាថ្នាក់ជាតិមួយសំរាប់បញ្ហាជំងឺកូវីដ-១៩។
- ○ នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងធ្វើការវាយតម្លៃទាក់ទងនឹងការត្រៀមខ្លួនរបស់ប្រព័ន្ធសុខាភិបាល នៅតាមមូលដ្ឋានថែទាំសុខភាព ទាក់ទងនឹងសមត្ថភាពសង្គ្រោះបន្ទាន់ (ICU) អុកស៊ីសែន បុគ្គលិកសុខាភិបាលជាដើម។
- កម្មវិធីថ្នាក់ជាតិកំពុងតែអភិវឌ្ឍផែនការឆ្លើយតប និងត្រៀមបង្ការដោយផ្តោតជាសំខាន់ទៅលើជំងឺកូវីដ-១៩។
- កំពុងដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រពង្រីកមន្ទីរពិសោធន៍ និងផែនការធ្វើរោគវិនិច្ឆ័យម៉ូលេគុលដើម្បីធានាឲ្យមានការធ្វើតេស្តគ្រប់គ្រាន់ជាប្រចាំសម្រាប់ជំងឺកូវីដ-១៩នៅថ្នាក់ជាតិ និងថ្នាក់តំបន់។
- ការស្ទង់មតិមួយកំពុងត្រូវបានធ្វើឡើងនៅគ្រប់ខេត្តទាំងអស់ស្តីអំពីការប្រើប្រាស់តេស្តរហ័ស។
- ពង្រឹងសមត្ថភាពត្រៀមបង្ការនៅថ្នាក់មូលដ្ឋាន ក្នុងករណីមានការផ្ទុះរាលដាលជំងឺនៅសហគមន៍នាពេលអនាគត និងដើម្បីកាត់បន្ថយការរាំងស្ទះដល់ដំណើរការផ្តល់សេវាសុខភាពសំខាន់ៗ។

### អភិក្រមយុទ្ធសាស្ត្រសម្រាប់បង្ការ ស្រាវជ្រាវ និងត្រួតពិនិត្យជំងឺកូវីដ-១៩

- ○ *យុទ្ធសាស្ត្រសម្រាប់ការធ្វើតេស្ត និងប្រព័ន្ធស្វែងរកអ្នកប៉ះពាល់មានរួចរាល់*

យុទ្ធសាស្ត្រធ្វើតេស្តទូលំទូលាយមួយ កំពុងត្រូវបានអនុវត្តនៅទូទាំងប្រទេស ដែលរួមមានការធ្វើតេស្តករណីសង្ស័យទាំងអស់ដែលចូលក្នុងនិយមន័យករណីសង្ស័យមានជំងឺកូវីដ-១៩ និងការឃ្លាំមើលយ៉ាងសកម្មចំពោះករណីជំងឺរលាកសាច់សួត (pneumonia) នៅតាមមន្ទីរពេទ្យ ក៏ដូចជាការធ្វើតេស្តនៅច្រកចេញ-ចូល (points of entry) នាថ្ងៃទី១ និងថ្ងៃទី១៣ ពេលបញ្ចប់ចត្តាឡីស័ក១៤ ថ្ងៃ និងការធ្វើតេស្តវត្ថុវិភាគបានមកពីប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI) ដើម្បីកំណត់រកមេរោគកូវីដ-១៩។ ការធ្វើតេស្តផ្តោតទៅលើក្រុមប្រជាជនដែលមានហានិភ័យខ្ពស់ (high-risk populations) កំពុងត្រូវបានអនុវត្តនៅពេលចាំបាច់។

- ○ *ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សគមន៍*

យុទ្ធសាស្ត្រសម្រាប់ស្រាវជ្រាវរកជំងឺដោយមានការចូលរួមរបស់សហគមន៍ ត្រូវបានបង្កើតឡើង និងដាក់សាកល្បងដើម្បីស្វែករកករណីជំងឺកូវីដ-១៩ នៅកម្រិតមណ្ឌលសុខភាព និងនៅក្នុងសហគមន៍។ ក្រសួងមហាផ្ទៃ កំពុងជម្រុញការត្រួតពិនិត្យការធ្វើចត្តាឡីស័កតាមរយៈការតាមដាន និងពិន័យសម្រាប់បុគ្គលដែលបំពានគោលការណ៍ណែនាំ។

- ○ *អន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ (មាននៅក្នុងតារាងនៅចុងបញ្ចប់នៃរបាយការណ៍នេះ)*

# បទពិសោធន៍ល្អៗ និងមេរៀនដែលទទួលបាន

### កត្តាដែលបានរួមចំណែកដល់ការឆ្លើយតបបានល្អ

- ○ **ភាពជាអ្នកដឹកនាំខ្លាំង និងការសម្របសម្រួលបានល្អ**
    - ○ ការឆ្លើយតបរបស់រដ្ឋាភិបាល និងសង្គមទាំងមូល ដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី ហើយវិធានការសុខភាពសាធារណៈដឹកនាំដោយរដ្ឋមន្ត្រីសុខាភិបាល។
    - ○ ផែនការមេថ្នាក់ជាតិសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានរៀបចំឡើងជាមួយនឹងថវិកាចំនួន ៦២លានដុល្លារសហរដ្ឋអាមេរិកសម្រាប់ឆ្នាំទី១។



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

  - កាលពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២១ សម្តេចនាយករដ្ឋមន្ត្រី បានដាក់ចេញនូវយុទ្ធសាស្ត្រស្តីអំពីការឆ្លើយតបចំពោះជំងឺកូវីដ-១៩ ចំនួន ៦ចំណុចដោយផ្តោតទៅលើការការពារមិនឲ្យមានការនាំចូលវីរុសកូវីដ-១៩បំប្លែងថ្មី ការកាត់បន្ថយភូមិសាស្ត្រដែលមានការរីករាលដាលនៃជំងឺកូវីដ-១៩ និងចំនួនករណីឆ្លង ការផ្តល់ការព្យាបាលប្រកបដោយប្រសិទ្ធភាព និងស្តង់ដារ ការពង្រឹងការស្វែងរក និងគ្រប់គ្រងអ្នកដែលប៉ះពាល់អ្នកជំងឺ ការចាត់ចែងសាកសព និងវ៉ាក់សាំងការពារជំងឺកូវីដ-១៩។
- **ការវិនិយោគកន្លងមកបានពង្រឹងដំណើរការប្រព័ន្ធសុខភាពសុខភាពសាធារណៈ**
  - ការតាមដានជំងឺកូវីដ-១៩ ដោយបានពីព័ត៌មានពហុប្រភព រួមទាំងប្រព័ន្ធឃ្លាំមើលជំងឺកូវីដ-១៩ ដោយប្រើប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (១១៥) និងប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI)។
  - ក្រុមឆ្លើយតបបន្ទាន់ជិត ៣.០០០នាក់ នៅទូទាំងប្រទេស បានស្រាវជ្រាវរកករណី និងតាមរកអ្នកប៉ះពាល់ជាមួយនឹងករណីវិជ្ជមានវីរុសកូវីដ-១៩។
- **ការទំនាក់ទំនង និងផ្សព្វផ្សាយហានិភ័យ និងការចូលរួមរបស់សហគមន៍**
  - សារទាន់ពេលវេលា ត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គម និងតាមរយៈសេចក្តីជូនព័ត៌មានទៀងទាត់ និងសន្និសីទសារព័ត៌មាន។
  - អភិក្រមដែលផ្អែកលើហានិភ័យសម្រាប់ការរៀបចំបង្កើតសម្ភារប្រាស្រ័យទាក់ទងជនគោលដៅ មានហានិភ័យខ្ពស់ ដូចជាជនទេសន្តប្រវេសន៍(ពលករចំណាកស្រុក) កម្មកររោងចក្រ ទីផ្សារលក់ដូរ ពន្ធនាគារ ភោជនីយដ្ឋាន-បារជាដើម ត្រូវបានបង្កើតឡើង។
  - យុទ្ធសាស្ត្រជម្រុញការចូលរួមរបស់សហគមន៍ ត្រូវបានអនុវត្តដើម្បីគ្របដណ្តប់គ្រប់ផ្នែកនៃការតាមដានជំងឺ និងការឆ្លើយតបចំពោះជំងឺកូវីដ-១៩ ជាពិសេសត្រៀមសម្រាប់ពេលមានការឆ្លងទៅសហគមន៍ណាមួយ។
  - មានកិច្ចសម្របសម្រួល និងសហប្រតិបិត្តការណ៍ជិតស្និទ ក្នុងចំណោមភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអ្នកពាក់ព័ន្ធដទៃទៀត នៅក្នុងការអនុវត្តសកម្មភាពការងារលើកកំពស់ការចូលរួមរបស់សហគមន៍ និងការប្រាស្រ័យទាក់ទងអំពីហានិភ័យ ការតាមដាន កែរសម្រួល និងពង្រឹងការអនុវត្ត។
- **សាមគ្គីភាព និងសហប្រតិបត្តិការអន្តរជាតិ**
  - ការឆ្លើយតបដោយប្រព័ន្ធសុខាភិបាលមួយដែលមានតម្លាភាព និងបើកចំហ។
  - កិច្ចសហការបច្ចេកទេស និងប្រតិបិត្តិការជិតស្និទ្ធរវាងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត។
  - ការចូលរួមនៃមន្ត្រីជាន់ខ្ពស់នៅកិច្ចប្រជុំអន្តរជាតិនានា រួមទាំងការសម្របសម្រួលជាទៀងទាត់ក្នុងចំណោមបុគ្គលិកទទួលបន្ទុកផ្នែកច្បាប់និយ័តកម្មអន្តរជាតិឆ្នាំ២០០៥ របស់អង្គការសុខភាពពិភពលោក។

## ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩

គិតត្រឹមថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២១៖

- រាជរដ្ឋាភិបាលកម្ពុជា ទទួលបានវ៉ាក់សាំងការពារជំងឺកូវីដ-១៩ សរុបចំនួន ២០.៤១៦.១០០ ដូស ដែលក្នុងនោះ៖
  - ចំនួន ១៥.៥០០.០០០ដូស ឬស្មើនឹង ៧៦ ភាគរយតាមរយៈការបញ្ជារទិញពីសាធារណរដ្ឋប្រជាមានិត្យចិន
  - ចំនួន ៣.២០០.០០០ដូស ឬស្មើនឹង ១៦ ភាគរយតាមរយៈជំនួយពីសាធារណរដ្ឋប្រជាមានិតចិន និង
  - ចំនួន ១.៧១៦.១០០ដូស ឬស្មើនឹង ៨ ភាគរយតាមរយៈជំនួយពីមជ្ឈមណ្ឌលកូវ៉ាក់ (ដោយបូកបញ្ចូលទាំងជំនួយពីរដ្ឋាភិបាលជប៉ុន និងសហរដ្ឋអាមេរិក)
- លទ្ធផលចាក់វ៉ាក់សាំងសម្រាប់បុគ្គលមានអាយុចាប់ពី ១៨ឆ្នាំឡើង
  - បុគ្គលសរុបចំនួន ៧.៤១៨.៤៥៣ (ស្ត្រី ៥០ ភាគរយ) បានទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩ដូសទី១ និងបុគ្គលចំនួន ៤.៩២៧.៨៧៦ (ស្ត្រី ៤៩ ភាគរយ) បានទទួលវ៉ាក់សាំងដូសទី២។ អត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងដូសទីមួយ គឺស្មើ



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

នឹង ៧៤ ភាគនៃប្រជាជនដែលនឹងត្រូវចាក់សរុប និងអត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងដូសទីពីរគឺស្មើនឹង ៤៩ ភាគរយនៃជនគោលដៅសរុប។

- លទ្ធផលចាក់វ៉ាក់សាំងសម្រាប់កុមារ និងយុវជនមានអាយុចាប់ពី ១២ឆ្នាំដល់អាយុក្រោម១៨ឆ្នាំ
  - កុមារ និងយុវជនចំនួនសរុប ៧៩.៦៧៦ (ឬស្មើនឹង ៤ ភាគរយ) ដែលមានអាយុពី ១២ឆ្នាំដល់អាយុក្រោម១៨ឆ្នាំ បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩។
- ព្រឹត្តិការណ៍មិនល្អក្រោយពេលចាក់វ៉ាក់សាំង (AEFI) ចំនួន ១៦៨ ករណី ត្រូវបានរាយការណ៍ពីខេត្តចំនួន ២១ និងមន្ទីរពេទ្យជាតិចំនួន ៤។ អត្រាព្រឹត្តិការណ៍មិនល្អក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស គឺមាន១,៣៦ ភាគរយ។
  - អត្រាព្រឹត្តិការណ៍មិនល្អក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំងស៊ីណូវ៉ាក់ (៧១ករណី) គឺមាន០,៩៥ ភាគរយ។
  - អត្រាព្រឹត្តិការណ៍មិនល្អក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំងស៊ីណូហ្វាម (៦៨ករណី) គឺមាន១,៥៤ ភាគរយ។
  - អត្រាព្រឹត្តិការណ៍មិនល្អក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំងអាស្ត្រាហ្សេណេកាកូរ៉ីសេល (២៩ករណី) គឺមាន៨,៩៧ ភាគរយ។
  - អត្រាព្រឹត្តិការណ៍មិនល្អក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំងអាស្ត្រាហ្សេណេកាផលិតនៅជប៉ុន (0ករណី) គឺមាន0,00 ភាគរយ។
  - អត្រាព្រឹត្តិការណ៍មិនល្អក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំង Johnson & Johnson (0ករណី) គឺមាន0,00 ភាគរយ។

## អន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ (Non-Pharmaceutical Interventions)

- កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបិទខ្ទប់ខេត្តចំនួន៨ ដែលរួមមាន ខេត្តកោះកុង ខេត្តពោធិសាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និងខេត្តសៀមរាប និងបានបានដាក់ចេញយុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បណ្តាលមកពីមេរោគបំប្លែងខ្លួនថ្មីប្រភេទដែលតា (Delta variant) នៅទូទាំងប្រទេសសម្រាប់រយៈពេល ១៤ថ្ងៃ ចាប់ពីថ្ងៃទី ២៩ ខែកក្កដា ដល់ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២១។
- កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ ២០២១ រដ្ឋមន្ត្រីសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានណែនាំឲ្យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំង២៥ អនុវត្តយុទ្ធនាការអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាពលរដ្ឋ ក្រោមប្រធានបទរួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ដើម្បីជម្រុញការទទួលខុសត្រូវរបស់បុគ្គល គ្រួសារ សហគមន៍ ស្ថាប័នពាក់ព័ន្ធជាពិសេសសេវាឯកជន អាជ្ញាធរមូលដ្ឋាន ក្នុងស្មារតីសាមគ្គីភាពដើម្បីកាត់ផ្តាច់ខ្សែចម្លងវីរុសកូវីដ-១៩ ព្រមទាំងរស់នៅជាមួយនឹងវីរុសកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មីឲ្យបានត្រឹមត្រូវ។
- កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០២១ រដ្ឋមន្ត្រីសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានណែនាំឲ្យអភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំង២៥ ដាក់ឲ្យប្រើនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ កម្រិតស្រាល និងគ្មានរោគសញ្ញានៅតាមផ្ទះ។
- កាលពីថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជូនដំណឹងដល់បងប្អូនពលករខ្មែរដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ឲ្យសហការផ្អាកការធ្វើដំណើរ ឬចល័តចេញពីដែលខ្លួនកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃឆ្ពោះមកព្រំដែនកម្ពុជា-ថៃចំនួន ១៤ថ្ងៃ ដោយសារព្រំដែនត្រូវបានបិទ ហើយឲ្យបងប្អូនពលករទាក់ទងទៅស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃប្រសិនបើមានបញ្ហានៅកន្លែងធ្វើការ ឬមានបញ្ហាជីវភាពលំបាកខ្លាំងក្នុងរយៈពេលស្នាក់នៅ និងធ្វើការនៅប្រទេសថៃ។
- កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០២១ ក្រសួងទេសចរណ៍ បានជូនដំណឹងអំពីការបន្តបិទសកម្មភាពអាជីវកម្ម KTV ក្លឹបកម្សាន្ត (ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន) និងអាជីវកម្មក្លឹបហាត់ប្រាណដើម្បីសុខភាពនៅក្នុង និងក្រៅសណ្ឋាគារនៅទូទាំងរាជធានី-ខេត្ត



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទេសចរណ៍ ហើយនិងផ្អាកសកម្មភាពរមណីយដ្ឋានទេសចរណ៍នៅទូទាំងប្រទេសជាបណ្តោះអាសន្នរយៈពេល ១៤ថ្ងៃចាប់ពីថ្ងៃទី ២៩ខែកក្កដា ដល់ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២១។

- ○ កាលពីថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០២១ រាជធានី-ខេត្តចំនួន ២២ លើកលែងតែខេត្តក្រចេះ ខេត្តមណ្ឌលគិរី និងខេត្តព្រៃវែង ដាក់អនុវត្តនូវយុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បណ្តាលមកពីមេរោគបំប្លែងខ្លួនថ្មីប្រភេទដែលតា (Delta variant) នៅទូទាំងប្រទេសដោយដាក់ចេញនូវវិធានការរដ្ឋបាលនានា។ វិធានការរដ្ឋបាលរួមដែលរដ្ឋបាលរាជធានី-ខេត្តភាគច្រើនបានដាក់អនុវត្ត រួមមានវិធានការដាក់ជាតំបន់មានហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ការផ្អាកជាបណ្តោះអាសន្នចំពោះសកម្មភាពការងារ មុខរបរ ឬអាជីវកម្មដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ការផ្អាកជាបណ្តោះអាសន្ននូវសកម្មភាពអាជីវកម្មផ្សាររដ្ឋ ការផ្អាកជាបណ្តោះអាសន្ននូវការជួបជុំ ឬការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជនដែលមានមនុស្សចូលរួមលើសពី១០នាក់ និងការអនុវត្តបម្រាមគោចរ។
- ○ កាលពីថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២១ រដ្ឋបាលរាជធានីភ្នំពេញ បានសម្រេចបិទខ្ទប់កំណាត់ផ្លូវលេខ ៩៣ ស្ថិតក្នុងក្រុមទី៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែទី១ ខណ្ឌឬស្សីកែវដែលសង្ស័យជាប់ពាក់ព័ន្ធនឹងមេរោគបំប្លែងខ្លួនថ្មីប្រភេទដែលតាចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី០៩ ខែសីហាឆ្នាំ២០២១ និងច្រកផ្លូវលេខ ៣៧២ ៣៧២Z និងផ្លូវលេខ ៣៦២ ស្ថិតក្នុងភូមិ៥ សង្កាត់បឹងសាឡាង ខណ្ឌទួលគោកដែលមានការឆ្លងរាលដាលនៃមេរោគបំប្លែងខ្លួនថ្មីប្រភេទដែលតា ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី១៦ ខែសីហាឆ្នាំ២០២១។
- ○ កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២១ រដ្ឋបាលខេត្តបាត់ដំបង បានសម្រេចបិទទីតាំងផ្សារចំនួន ៤៩ (ភាគច្រើនបំផុតជាទីតាំងផ្សាររដ្ឋ) នៅទូទាំងខេត្តចាប់ពីថ្ងៃទី ០១ រហូតដល់ថ្ងៃទី ១៤ ខែសីហា អនុលោមទៅតាមសារាចររបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ឲ្យអនុវត្តយុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បណ្តាលមកពីមេរោគបំប្លែងខ្លួនថ្មីប្រភេទដែលតា (Delta variant) នៅទូទាំងប្រទេសសម្រាប់រយៈពេល ១៤ថ្ងៃ។
- ○ ក្នុងរយៈពេលមួយសប្តាហ៍កន្លងមកនេះ ទីតាំងផ្សារចំនួន ៩នៅក្នុងខេត្តចំនួន៤ ត្រូវបានបិទជាបណ្តោះអាសន្ន ខណៈដែលទីតាំងផ្សារផ្សារលើស្ថិតនៅក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំងត្រូវបានអនុញ្ញាតឲ្យបើកដំណើរការឡើងវិញ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី២ . ការអនុវត្តអន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ និងថ្ងៃដែលលើកបម្រាមវិញ (NPI implementation and lifting dates)**

| អន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ (NPI) | ស្ថានភាពត្រួតពិនិត្យ (Monitoring status) | | | | | |
|---|---|---|---|---|---|---|
| | | | ការអនុវត្ត (Implementation) | | ការលើកបម្រាមវិញដោយផ្នែក (Partial lift) | លើកបម្រាមវិញ (Lifted) |
| | ថ្ងៃទី១នៃការអនុវត្ត (Date first implemented) | ថ្ងៃកែប្រែចុងក្រោយ (Date last modified) | ភូមិសាស្ត្រ (ថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ) Geographical (national or sub-national) | ណែនាំឲ្យ ឬតម្រូវឲ្យ (Recommended or Required) | លើកសម្រាប់វិស័យ/ផ្នែកខ្លះ (Lifted for some area) | លើកសម្រាប់វិស័យ/ផ្នែកទាំងអស់ (Lifted for all areas) |
| ពាក់ម៉ាស់ការពារ អនាម័យដៃ និងផ្លូវដង្ហើម | មិនមានទេ (None) | ០៣ ឧសភា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | | មិនទាន់លើកទេ (No) |
| បិទសាលារៀន (School Closure) | ១៦ មិនា ឆ្នាំ២០២០ | ១៩ មិថុនា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | មិនទាន់លើកទេ (No) | មិនទាន់លើកទេ (No) |
| បិទកន្លែងធ្វើការ (Workplace Closure) | មិនមានទេ (None) | មិនមានទេ (None) | | | | |
| ការជួបជុំមនុស្សម្នាច្រើន (Mass Gatherings) | ៣ មេសា ឆ្នាំ២០២០ | ១៩ មិថុនា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | មិនទាន់លើកទេ (No) | មិនទាន់លើកទេ (No) |
| នៅផ្ទះ (Stay at Home) | រដ្ឋាភិបាលស្នើឲ្យនៅផ្ទះប្រសិនបើអាចធ្វើបាន (Government recommends stay home if possible) | មិនមានទេ (None) | | | | |
| រឹតបន្តឹងការធ្វើដំណើរនៅក្នុងប្រទេស (Restrictions on Internal Movement (within country)) | ៩ មេសា ឆ្នាំ២០២០ | ២៩ កក្កដា ឆ្នាំ២០២១ | ថ្នាក់ជាតិ | ណែនាំឲ្យ (Recommended) | បានលើកហើយ (Yes) | មិនទាន់លើកទេ (No) |
| ការរឹតបន្តឹងលើការធ្វើដំណើរអន្តរជាតិ (Restrictions on International Travel) | ២៧ មិនា ឆ្នាំ២០២០ | ១១ វិច្ឆិកាឆ្នាំ២០២០ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | បានលើកហើយ (Yes) | មិនទាន់ទេ (No) |
| ផ្សេងៗទៀត សូមបញ្ជាក់ដោយពណ៌នា (Others; specify in narrative) | មិនមានទេ (None) | មិនមានទេ (None) | - | - | - | - |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។